# បញ្ហា នៃ ការបោះឆ្នោត

**Les enjeux des élections**

ថ្ងៃទី ២០ ឧសភា ជា ថ្ងៃ បើក ជា ផ្លូវការ នូវ យុទ្ធការ នៃ ការ បោះឆ្នោត ឃុំ-សង្កាត់ សំរាប់ គណបក្ស ទាំង ១២ ដែល បានចុះ ឈ្មោះ ចូលប្រកួតប្រជែង ដណ្តើម អាសន: ទីព្រឹក្សា។ លោក កឹ ម សុខា ប្រកាសថា គាត់ ទុកចិត្ត លើ គ.ជ.ប. ថា អាច ការពារ អោយមាន ការបោះឆ្នោត ដោយ សេរី និង យុត្តិធម៌។ ព្រះមហា ក្សត្រ តម្រាស់ លើកទឹកចិត្ត ប្រជាពលរដ្ឋ អោយ ទៅបោះឆ្នោត ជ្រើសរើស តាមសេរី កុំអោយមានចិត្តរអា ពីការគំរាមគ្រប់ បែបយ៉ាង ពីអ្នកដទៃ។ លោក ហ៊ុន សែន បង្គាប់ដល់ អាជ្ញាធរ អោយ រក្សា សន្តិសុខ នៅពេលបោះឆ្នោត។ ហើយ គ្រប់ មេ គណ បក្ស ចេញ ឃោសនា រៀងៗខ្លួន ក្នុងក្បួនយ៉ាងអ៊ឹកធឹក ហាក់ បីដូចជាស្រុកខ្មែរ ជា ប្រទេស ប្រជាធិបតេយ្យ មាន នីតិរដ្ឋ សំ រាប់ ការពារ សិទ្ធិសេរីភាពប្រជាពលរដ្ឋ។ តែ ខ្មែរយើង មាន ស្មារតីខ្ជី ព្រោះថា ម្សិលម្ចិញ លោក ហ៊ុន សែន ប្រកាសថា បើ គណបក្ស របស់គាត់ ចាញ់ឆ្នោត នឹងមានសង្គ្រាម ហើយ, លោក កុងរ៉ូ ក្រសួងការពារជាតិ ថា បើ មាន អ្នកណា ហ៊ានតវ៉ា ថាពួកខ្លួន ជា អ្នកឈ្នះ គាត់នឹងវ៉ែនតានោះអោយបាក់ធ្លេញ ហើយ, អ្នកនាំពាក្យ គណបក្សកាន់អំណាច ថ្លែងថា គណបក្ស ណា ប្រើពាក្យស្លោក « ដូរ ឬ មិន ដូរ » ឬ « ហ៊ុន សែន អើយ ចុះ

ចេញទៅ » នឹងត្រូវទទួលទោស ហើយ, អគ្គមេបញ្ជាការ កងទ័ព ខេមរ:ភូមិន្ទ ពោលអះអាង ថា កងទ័ពជាតិ ជា កងទ័ពបក្ស ប្រជាជនកម្ពុជា ហើយ, អ្នកខ្វែងមតិ ត្រូវ គេសម្លាប់ ហើយ, នៅក្នុងគុកព្រៃស មាន អ្នកទោស នយោបាយ... ។ល។ ភាពផ្ទុយគ្នាស្រឡះ រវាង បរិយាកាសណ៍ នៃ មហោស្រពនៅកំឡុង យុទ្ធការបោះឆ្នោត នឹងបរិបទ នៃ អំណាចផ្តាច់ការ មាន ជាក់ស្តែង ចោទជា ចំណោទ នៃ សមូហសតិសម្បជញ្ញ:[1] របស់ខ្មែរយើង គឺថា តើ ប្រជាពលរដ្ឋខ្មែរ កំពុងយល់ច្រឡំ អំពី អត្ថរស់ នៃ លទ្ធិ ប្រជាធិបតេយ្យ ? គេដឹងថា តាម ការពិសោធន៍ ការបោះឆ្នោត រៀបចំឡើង នៅក្នុង របបផ្តាច់ការ គឺគ្រាន់ជា គោលវិធីមួយ សំរាប់តែ ដឹកនាំ ទៅរក អំពើហិង្សា ឬ សំរាប់តែ រាយរាប់ ចំនួន គណបក្ស ចូលរួមបោះឆ្នោត ឬ សំរាប់តែ ប្រកាស ជ័យជំនះ របស់ គណបក្សកាន់អំណាច តែប៉ុណ្ណោះ។ បើ ប្រជាពលរដ្ឋខ្មែរ យក ការពិសោធន៍ នៃ ការបោះឆ្នោត ពីមុនៗមក មកធ្វើជា មេរៀន គឺ ច្បាស់ « ទុកជា ជ័យជំនះ នៃ ការសង្ឃឹម លើ ការ ពិសោធន៍[2] » ព្រោះ ការបោះឆ្នោត ទាំងឡាយ តាំងពីឆ្នាំ ១៩៩៣ តែងតែជា សេចក្តីអស់សង្ឃឹម ដ្បិត អ្វីដែលខ្លួន ចង់ បាន វា មិនដែល ទទួលបាននោះឡើយ។ ដូច្នេះ បន្ត ចូលរួម បោះឆ្នោត នៅក្នុង បរិបទដដែល វា នឹងទទួល លទ្ធផលដដែល

---

[1] សមូហសតិសម្បជញ្ញ: ; conscience collective។

[2] ទុកជា ជ័យជំនះ នៃ ការសង្ឃឹម លើ ការពិសោធន៍ ; c'est le triomphe de l'espérance sur l'expérience។

## បញ្ហា នៃ ការបោះឆ្នោត

គឺ ថា « ទុកជា បរាជ័យ នៃ សេចក្ដីសង្ឃឹម លើ ការពិសោធន៍ » នៅក្នុង បរាជ័យនេះ រាហាក់បីដូចជា ប្រជាជនខ្មែរ ជា អ្នក ទទួលរងគ្រោះ ក្រាបបែបយ៉ាង ពីសំណាក់អំណាចផ្តាច់ការ គ្មាន លទ្ធភាព កសាងបានដោយខ្លួនឯង នូវ សង្គម គ្មាន ការគាប សង្កត់ ពី ពួកជនផ្តាច់ការ។ ដូច្នេះ ការចូលរួមបោះឆ្នោត គឺ « ទុកជា ជ័យជំនះ នៃ អំណាចផ្តាច់ការ លើ ការពិសោធន៍ នៃ ប្រជាពលរដ្ឋខ្មែរ » ជ័យជំនះ នេះឯង ជា ការយល់ច្រឡំ អំពី អត្ថរស់ នៃ លទ្ធិប្រជាធិបតេយ្យ គឺ ទុក ការបោះឆ្នោត នៅ ក្រោមការដឹកនាំ នៃ របបព្រៃ ជា ដំណោះស្រាយ នៃ បញ្ហា សង្គមកិច្ច និង នយោបាយ។ តែ ផ្ទុយទៅវិញ រារិតតែ ធ្វើអោយ ពួកជនពាល មាន លទ្ធភាព ពង្វឹកបន្ថែម នូវ អំពើហិង្សា ដើម្បី ពង្រឹង អំណាចផ្តាច់ការ។ តាមការពិសោធន៍នេះឯង ដែល បង្ហាញអោយឃើញ នូវ បញ្ហា នៃ ការបោះឆ្នោត ដែល កំពុងប្រព្រឹត្ត នៅស្រុកខ្មែរបច្ចុប្បន្ន គឺថា ដូចជា ប្រជាពលរដ្ឋ ខ្មែរកំពុងប្រឆាំងនឹង លទ្ធិប្រជាធិបតេយ្យ, សិទ្ធិមនុស្ស, សេរី ភាពក្នុងការបញ្ចេញមតិ និង ការបោះឆ្នោតសាកល តែម្តង ព្រោះ សុខចិត្តបន្តចូលរួម បោះឆ្នោត គ្មាន សេរី និង យុត្តិធម៌។ រីឯ ពួកអ្នកនយោបាយ វិញ, អវត្តមាន នៃ ការពិសោធន៍ ប្រចិត្ត ក្នុង ស្មារតី របស់ពួកគាត់ គឺ ជា សមូហអត្តឃាតកម្ម នៅចំពោះមុខ អំណាចហ៊ុនសែន។ នៅក្នុងបរិបទបែបនេះ ខ្មែរយើង កំពុងតែនាំគ្នា ប្រគល់ ទឹកដីជាតិ អោយទៅប្រជា ជនយួន។ ពុទ្ធោ នេះរឺ ហៅថា កម្ម អនន្តខ្មែរ !